ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..៧០៣......សហវ.ភស

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១១

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**កម្មវត្ថុ:** ករណីសំណើថវិកាចំនួន ៤.៧៣៧.៣៨១,២៤ដុល្លាអាមេរិក សម្រាប់គម្រោងជួសជុលស្តារឡើងវិញ ប្រឡាយមេព្រែកជីក ក្នុងខេត្តបាត់ដំបង ។

**យោង:** លិខិតលេខ ២៥៥៦ ធទឧ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន៤.៧០០.០០០,០០ដុល្លារអាមេរិក (បួនលានប្រាំពីររយពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយមដើម្បីជួសជុលស្តារឡើងវិញប្រឡាយមេព្រែកជីក (តាមសំណើនៃគំនូសប្លង់) ស្ថិតក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 0132-CAM(SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_sdm@yahoo.com